**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ...៥៧៣.......អ.ន.ក

ថ្ងៃព្រហស្បតិ៍...១០កើត...ខែជេស្ឋ...ឆ្នាំច...សំរឹទ្ធិស័ក...ព.ស.២៥៦២...
រាជធានីភ្នំពេញ ថ្ងៃទី...២៤...ខែឧសភា........ឆ្នាំ២០១៨...

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុះ** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែមេសា ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំខែមេសា ឆ្នាំ២០១៨ មានដូចខាងក្រោមៈ

**I.លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨**

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ៥៤៨.៧៥៩ ហ.ត ស្មើនឹង១២៣,៦៨% នៃផែនការចំនួន ៤៤៣.៧០០ ហ.ត ច្រើនជាងឆ្នាំមុនចំនួន ៣០.០៣០ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ៥៦១.០៦៩ ហ.ត តិចជាងឆ្នាំមុនចំនួន ៣.៣៧៤ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ៥៤៨.៧៩២ ហ.ត ស្មើនឹង៩៧,៨១%
- ផ្ទៃដីសាបសរុប : ៤៧៩ ហ.ត តិចជាងឆ្នាំមុនចំនួន ៧៧ ហ.ត
- ការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៧-២០១៨ : ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានលើផ្ទៃដី ៥៤៧.៨៥២ ហ.ត ស្មើនឹង៩៩,៨៣% នៃផ្ទៃដីអនុវត្ត ដែលទទួលបានទិន្នផលមធ្យម៤,៤៩ តោន/ហ.ត និងបរិមាណផលសរុប ២.៤៦៤.៧៣៥ តោន។







*ក្រាហ្វិកៈ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវប្រាំងពីឆ្នាំ២០១៤-២០១៨ គិតត្រឹម ចុងខែមេសា នៃឆ្នាំ*

តាមក្រាហ្វិកខាងលើបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំដូចគ្នាគិតត្រឹមចុងខែមេសា ផ្ទៃដីភ្ជួររាស់រដូវប្រាំងឆ្នាំ២០១៨ មានចំនួនច្រើនជាងឆ្នាំ២០១៤ និងឆ្នាំ២០១៦ ប៉ុន្តែតិចជាងឆ្នាំ២០១៥ និងឆ្នាំ២០១៧។ ដោយឡែកការងារដាំដុះស្រូវរដូវប្រាំងឆ្នាំ២០១៨នេះ មានចំនួនច្រើនជាងបណ្តាឆ្នាំមុនៗ បើប្រៀបធៀបរយៈពេលដូចគ្នា៥ឆ្នាំចុងក្រោយ។

**២. ដំណាំរួមផ្សំ** : អនុវត្តបានចំនួន ១២៧.២៣១ ហ.ត ច្រើនជាងឆ្នាំមុនចំនួន ២៦.០៤៧ ហ.ត។



អាសយដ្ឋានលេខៈ ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខៈ(០២៣) ៨៨៣ ៤២៧ ទូរសារលេខៈ(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427